**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ២០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការងារសម្បទាន និងស្តារផ្លូវដែកកម្ពុជា ក្រោមហិរញ្ញប្បទានធនាគារអភិវឌ្ឍន៍អាស៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមនស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការដាក់រាជាយស្ម័យយានកម្ពុជា ជាសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៣២ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគំរោងផ្លូវដែកសិង្ហបុរី-គុនមីង
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយថវិកាកម្ចីធនាគារអភិវឌ្ឍន៍អាស៊ី
- បានឃើញអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីគម្រោងស្តារជួសជុលឡើងវិញផ្លូវដែកកម្ពុជា ដែលបានចុះហត្ថលេខា នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការធ្វើសម្បទានរាជាយស្ម័យយានកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងការងារសម្បទាន និងស្តារផ្លូវដែកកម្ពុជា សរសេរកាត់ថា **គ ស ស ផ ក** ជាភាសាអង់គ្លេសហៅថា Committee for the Management of the Concession and the Rehabilitation of the Cambodian Railway–CMCR ដែលស្ថិតក្រោមការចង្អុលទិស និងកំណត់គោលនយោបាយរបស់គណៈកម្មាធិការជាតិគំរោងផ្លូវដែកសិង្ហបុរី-គុនមីង ដែលជាយន្តការគ្រប់គ្រងដឹកនាំរួម ដើម្បីជំរុញប្រសិទ្ធភាពការងារគ្រប់គ្រងសម្បទានផ្លូវដែកក្នុងរយៈពេលនៃកិច្ចព្រមព្រៀងសម្បទាន និងការអនុវត្តគំរោងស្តារឡើងវិញផ្លូវដែកទាំងពីរទិសរបស់កម្ពុជា ពីភ្នំពេញ-ក្រុងព្រះសីហនុ និងភ្នំពេញ-ប៉ោយប៉ែត ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

## ជំពូកទី ២

## សមាសភាព តួនាទី និងភារកិច្ច

**មាត្រា ២.-**

**គ ស ស ផ ក** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ទ្រាំ អ៊ីវតេក | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្តម តូច ចាន់កុសល | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- ឯកឧត្តម វង្ស៊ី វិស្សុត | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-ឯកឧត្តម សុខុម ភគវន្តមុនី | ប្រធានអគ្គនាយករាជាយស្ម័យយានកម្ពុជា | សមាជិក |
| ៥- ឯកឧត្តម គីមហ៊ែ សំអេច | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យឯកឧត្តម | |

| | | |
|---|---|---|
| | ឧបនាយករដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ៦-លោក យិត មុន្នា | ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧-លោក វ៉ែន សុទិដ្ឋារ៉ោ | អគ្គនាយករង អគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨- លោក នេត្រ មុន្នី | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩-លោក ឈន សុភាព | ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយគំរោងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**មាត្រា ៣.-**

**គ ស ស ផ ដ** មានភារកិច្ចដូចខាងក្រោម ៖

- ដឹកនាំការអនុវត្តគោលនយោបាយឯកជនភាវូបនីយកម្មផ្លូវដែករបស់រាជរដ្ឋាភិបាលកម្ពុជា
- ដឹកនាំគ្រប់គ្រងគណៈកម្មការគ្រប់គ្រងសម្បទានផ្លូវដែក
- ទទួលបន្ទុកការងារផ្ទេរទ្រព្យសម្បត្តិផ្លូវដែក និងមន្ត្រី និយោជិត កម្មករ ផ្លូវដែកទៅឱ្យសម្បទានិក
- គ្រប់គ្រងការងារស្តារបណ្តាញផ្លូវដែក ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី
- គ្រប់គ្រងក្រុមហ៊ុនប្រតិបត្តិការសម្បទាន តាមរយៈគណៈកម្មការសម្បទានផ្លូវដែក ដើម្បីធានាឱ្យមានការអនុវត្តស្របតាមកិច្ចសន្យាសម្បទានរបស់រាជរដ្ឋាភិបាល
- ណែនាំ និងដោះស្រាយរាល់បញ្ហាក្នុងការងារគ្រប់គ្រងរបស់អង្គភាពផ្លូវដែកដែលសេសសល់ក្រោយការប្រគល់សម្បទានឱ្យសម្បទានិក
- ដោះស្រាយ-សម្របសម្រួលរាល់បញ្ហាដែលកើតមានឡើងនៅក្នុងដំណើរការនៃសម្បទានផ្លូវដែក
- ត្រូវធ្វើសេចក្តីរាយការណ៍លំអិតជូនគណៈកម្មាធិការជាតិ គម្រោងផ្លូវដែកសឹង្ហបុរី-គុនមីញ

**មាត្រា ៤.-**

គណៈកម្មាធិការគ្រប់គ្រងការងារសម្បទាន និងស្តារឡើងវិញផ្លូវដែកកម្ពុជា ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ៥.-**

ដើម្បីឱ្យ **គ ស ស ផ ដ** ដំណើរការមានប្រសិទ្ធភាព ត្រូវបានកែសម្រួលគណៈកម្មាធិការគ្រប់គ្រងសម្បទាន ដែលត្រូវបានបង្កើតដោយអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ និងកែសំរួលតាមអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៧មកជា **គណៈកម្មការគ្រប់គ្រងសម្បទានផ្លូវដែក** ជាភាសាអង់គ្លេសហៅថា Concession Management Committee- CMC ដែលមាន សមាសភាពកែសម្រួលដូចខាងក្រោម ៖

| | | |
|---|---|---|
| ១ -ឯកឧត្តម ទូច ចាន់កុសល | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២ -ឯកឧត្តម ចន្ធី ទីសុវត្ថ | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម ជា ចាន់ដេត | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ៤ - ឯកឧត្តម តឹកអៀត សំអេច | ទីប្រឹក្សានិងជានាយករងខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ៥- ឯកឧត្តម ស៊ុយ សាន | អគ្គាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦- លោក ចាន់ សុធី | ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧ - លោក ចាំស៊ីង សុរិយា | ប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨ - លោក អ៊ុន អ៊ួក | ប្រធានផ្នែកអាជីវកម្ម រាជាយស្ម័យយានកម្ពុជា | សមាជិកមិនអនុម័ត |
| ៩ - លោក សុខ សុវណ្ណា | អនុការិ.និទិតភ័ណ្ឌ រាជាយស្ម័យយានកម្ពុជា | សមាជិកមិនអនុម័ត |

**មាត្រា ៦.-**

ភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងសម្បទានផ្លូវដែក ត្រូវបានកែសម្រួលដូចខាងក្រោម :

- ពិនិត្យ និងវាយតម្លៃលើឯកសារលទ្ធកម្ម របស់ហេដ្ឋារចនាសម្ព័ន្ធដែលបានស្តារឡើងក្រោមហិរញ្ញប្បទាន របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីផ្តល់យោបល់ជូន គ ស ស ជ ក ក្នុងការផ្តល់សម្បទានដល់ សម្បទានិកផ្លូវដែក
- ដឹកនាំការផ្ទេរ និងគ្រប់គ្រងទ្រព្យសម្បទាន និងមន្ត្រី និយោជិត កម្មករ ផ្លូវដែកកម្ពុជាដែលត្រូវផ្ទេរទៅ ឱ្យសម្បទានិកក្រោមការណែនាំរបស់ គ ស ស ជ ក ក្នុងរយៈពេលសម្បទាន
- គ្រប់គ្រងកិច្ចសន្យាសម្បទានផ្លូវដែកក្នុងរយៈពេលនៃកិច្ចសន្យាសម្បទាន
- គ្រប់គ្រងការងារស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក តាមរយៈអង្គភាពអនុវត្តគម្រោងស្តារផ្លូវដែក
- ដឹកនាំសម្របសម្រួលការងារសាងសង់កំណាត់ផ្លូវដែកពីស៊ីសុផុន-ប៉ោយប៉ែត និងការតភ្ជាប់ផ្លូវដែក ជាមួយប្រទេសថៃនៅប៉ោយប៉ែត
- មានតួនាទីជាលេខាធិការដ្ឋានរបស់ គ ស ស ជ ក និងបូកសរុបរបាយការណ៍ស្តីពីសកម្មភាពការងារ របស់ខ្លួន និងរបស់អង្គភាពអនុវត្តគម្រោងស្តារផ្លូវដែកជូន គ ស ស ជ ក ។

**មាត្រា ៧.-**

គណៈកម្មការគ្រប់គ្រងសម្បទានផ្លូវដែក មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ចំពោះការងារដែលបានការឯកភាពពី គ ស ស ជ ក ។

## មាត្រា ៨.-

ត្រូវបានកែសម្រួលឈ្មោះក្រុមការងារអនុវត្តគំរោងស្តារផ្លូវដុលហោង្ខារបទាសម្ព័ន្ធផ្លូវដែកកម្ពុជាដែលត្រូវបានបង្កើតដោយអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ មកជា **អង្គភាពអនុវត្តគំរោងស្តារផ្លូវដែកក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី** ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មការគ្រប់គ្រងសម្បទានផ្លូវដែក ដែលមានសមាសភាពកែសម្រួលដូចខាងក្រោម :

| | | |
|---|---|---|
| ១ - លោក **ឃិត មុន្នីរ៉ា** | ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស ក្រសួងសាធារណការ និងដឹកជញ្ជូន | នាយកគំរោង |
| ២ - លោក **លី ម៉ូរិន** | នាយកផ្លូវ ស្ពានអាគារ នៃរាជាយស្ម័យយានកម្ពុជា | ប្រធានគ្រប់គ្រងបច្ចេកទេស |
| ៣ - លោក **ចាន់ សំឡេង** | នាយករងផ្លូវស្ពានអាគារ នៃរាជាយស្ម័យយានកម្ពុជា | ប្រធានគ្រប់គ្រងទូទៅ |
| ៤ - លោក **ង៉ែត ម៉ុនតឹក** | ប្រធានបណ្តាញផ្លូវដែកពាយព្យទិស នៃ រាជាយស្ម័យយានកម្ពុជា | ទទួលបន្ទុកបណ្តាញផ្លូវដែក ភ្នំពេញ-ប៉ោយប៉ែត |
| ៥ - លោក **ម៉េង លី** | ប្រធានទទួលបន្ទុកសិល្បការ្យ និងស្ថាបនាថ្មី នៃរាជាយស្ម័យយានកម្ពុជា | ទទួលបន្ទុកបណ្តាញផ្លូវដែក ភ្នំពេញ-ក្រុងព្រះសីហនុ |
| ៦ - លោក **អ៊ិន ទៀងសុផល** | នាយរងការិ.មជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសក្រសួងសាធារណការដឹកជញ្ជូន | ទទួលបន្ទុកលទ្ធកម្ម-គណនេយ្យករ |
| ៧ - លោក **នូ មុន្នី** | នាយការិ. មជ្ឈមណ្ឌលស្រាវជ្រាវ បច្ចេកទេសក្រសួងសាធារណការដឹកជញ្ជូន | ទទួលបន្ទុករដ្ឋបាល |
| ៨ - លោក **វុត្ថ សារ៉ាន** | អនុប្រធាននាយកដ្ឋានរដ្ឋបាល | ជំនួយការរដ្ឋបាល |
| ៩ - លោក **ត្រាំ ណាវ៉ាន់** | មន្ត្រីខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង ស.ក.ដ.ជ | ជំនួយការលទ្ធកម្ម-គណនេយ្យ |
| ១០- លោក **ឡូត ឧត្តមីជា** | មន្ត្រីនាយកដ្ឋានផែនការក្រសួង ស.ក.ដ.ជ | ជំនួយការរដ្ឋបាល |

## មាត្រា ៩.-

អង្គភាពអនុវត្តគំរោងស្តារផ្លូវដែក ត្រូវបានកែសម្រួលភារកិច្ចដូចខាងក្រោម :

- សហការជាមួយទីប្រឹក្សាត្រួតពិនិត្យបច្ចេកទេសគំរោងស្តារឡើងវិញផ្លូវដែកទាំងពីរទិសភ្នំពេញ-ក្រុងព្រះសីហនុ និងភ្នំពេញ-ប៉ោយប៉ែត លើការងារលទ្ធកម្ម និងការសាងសង់
- គ្រប់គ្រងក្រុមហ៊ុនសាងសង់ផ្លូវដែក
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីដោះស្រាយរាល់ការងារ និងបញ្ហាដែលពាក់ព័ន្ធនឹងការស្តារឡើងវិញផ្លូវដែកកម្ពុជា
- រាយការណ៍ជូនគណៈកម្មការគ្រប់គ្រងសម្បទានផ្លូវដែកជាប្រចាំរៀងរាល់ខែ និងបូកសរុបប្រចាំឆ្នាំ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

មាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងស្តារ ជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងឥណទានធនាគារអភិវឌ្ឍន៍អាស៊ី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ